ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៣៤/១៣-អិម អេច បាយអូ -អេនើជី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ម៉ែន និម្មិត**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ៥ សង្កាត់ព្រែកព្នៅ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ២១៥ ៣៦១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ ៖

១- លោក អោង សុភ័ក្រ្ត បុគ្គលិករដ្ឋបាល

២- លោក ទុយ ហួ ប្រធានផ្នែកផលិតកម្ម

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖**-សហព័ន្ធសហជីពអំណាចកម្មករខ្មែរ**

**-សហជីពអំណាចកម្មករខ្មែរក្រុមហ៊ុន អិម អេច បាយអូ អេនើជី**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ៤ ផ្ទះលេខ២ជី ភូមិបុរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៩២ ៩៥៧ ៤៧២ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥ ២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

| | |
|---|---|
| ១- លោក ព្រុំ ប៊ុនធឿន | អនុប្រធានសហព័ន្ធសហជីពអំណាចកម្មករខ្មែរ |
| ២- លោក ឡោ សុភក្រ្ត | អគ្គលេខាធិការសហព័ន្ធសហជីពអំណាចកម្មករខ្មែរ |
| ៣- លោក គង់ រ៉ុម | ប្រធានសហជីពអំណាចកម្មករខ្មែរក្រុមហ៊ុន អិមអេច បាយអូ អេនើជី |
| ៤- លោក ចាប សារ៉េត | អនុប្រធានសហជីពអំណាចកម្មករខ្មែរក្រុមហ៊ុន អិម អេច បាយអូ អេនើជី |
| ៥- លោក ឡេង ម៉េងលាង | ជំនួយការសហជីពអំណាចកម្មករខ្មែរក្រុមហ៊ុន អិម អេច បាយអូ អេនើជី |
| ៦- លោក ស្រេង ស្រីន | ជំនួយការសហជីពអំណាចកម្មករខ្មែរក្រុមហ៊ុន អិម អេច បាយអូ អេនើជី |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ ជូនកម្មករនិយោជិត។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា មិនអាចផ្តល់ជូនបានទេ។

២- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់អតីតភាពការងារជូនកម្មករនិយោជិត ។ ដោយឡែកភាគីក្រុមហ៊ុនបានបញ្ជាក់ថា មិនអាចផ្តល់ជូនបានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៧៧៧ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣។

THE ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងពីសហព័ន្ធសហជីពអំណាចកម្មករខ្មែរ ស្តីពីការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ០៦ ចំណុច។ ចំណុចមិនសះជាចំនួន ០២ ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជា លេខ ៧៧៧ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០១៣ ហើយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន ០២ ចំណុចនេះ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៣ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០២ ចំណុចនេះបន្ថែមទៀត ប៉ុន្តែមិនទទួលបានការសះជាលើចំណុចវិវាទទាំងនេះទេ។

សេចក្តីបង្គាប់ក្នុងសំណុំរឿងនេះ ជាសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- វិញ្ញាបនបត្រប័ញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី លេខ ០៧៤៥ ពណ.ចបព ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣។

២- អនុស្សរណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី តំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម លេខ ១៥៨៥/០៦ ពណ.ចបព ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២។

៣- លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ របស់អ្នកគ្រប់គ្រងទូទៅក្រុមហ៊ុន អិម អេច បាយអូ អេនើជី ប្រគល់សិទ្ធិជូនលោក ទុយ ហោ និងលោក អោង សុភ័ក្ត្រ ជាតំណាងចូលរួមសវនាការនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ១៤៖០០។

៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អិមអេច បាយអូ អេនើជី ចុះបញ្ជិកាលេខ ០៨៩/០៩ ក.ប.វ ចុះថ្ងៃទី ១១ ខែឧសភា ឆ្នាំ២០០៩។

៥- លិខិត ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការស្រាយបំភ្លឺនូវវិវាទការងារ ដែលកើតមានឡើង រវាងកម្មករនិយោជិត និងនិយោជក។

៦- សេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

៧- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតលេខ ០៤៨/១៣/ស.ស.អ.ក.ខ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ របស់សហពន្ធ័សហជីពអំណាចកម្មករខ្មែរ គោរពជូនប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើសុំដោះស្រាយនូវលក្ខខណ្ឌការងារមួយចំនួនរបស់កម្មករនិយោជិតក្រុមហ៊ុន អិម អេច បាយអូ អេនើជី (M.H Bio Energy Co.,ltd) ។

២- លិខិតលេខ ០៤១/១៣/ស.ស.អ.ក.ខ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ របស់សហពន្ធ័សហជីពអំណាចកម្មករខ្មែរ គោរពជូន នាយកក្រុមហ៊ុន អិម អេច បាយអូ អេនើជី (M.H Bio Energy Co.,ltd) ស្តីពីសំណើជួបចរចាដើម្បីដោះស្រាយនូវសំណូមពររបស់បុគ្គលិកក្រុមហ៊ុន អិម អេច បាយអូ អេនើជី (M.H Bio Energy) ។

៣- លិខិតពឹងពាក់ និងផ្ទេរសិទ្ធិ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ របស់កម្មករនិយោជិត និងបុគ្គលិកក្រុមហ៊ុន អិម អេច បាយអូ អេនើជី (M.H Bio Energy) ជូនប្រធានសហពន្ធ័សហជីពអំណាចកម្មករខ្មែរ ដើម្បីជួយដោះស្រាយរកយុត្តិធម៌ និងទាមទារនៅលក្ខខណ្ឌការងារមួយចំនួនពីក្រុមហ៊ុន អឹមអេច បាយអូ អេនើជី ។

៤- បង្កាន់ដៃទទួលសំណុំរឿង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣ របស់នាយកដ្ឋានវិវាទការងារ ដែលបានទទួលពីសហជីពអំណាចកម្មករខ្មែរ ដើម្បីសុំជួយដោះស្រាយវិវាទ។

៥- កាតសំគាល់ខ្លួនរបស់កម្មករនិយោជិតបំរើការងារនៅក្រុមហ៊ុន អិម អេច បាយអូ អេនើជី ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អិម អេច បាយអូ អេនើជី លេខ ៧៧៧ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អិម អេច បាយអូ អេនើជី ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៦៧៥ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៦៧៦ កប/អក/វក/លកអ. ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៣។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- យោងតាមអនុស្សារណៈ និងលក្ខន្តិកៈរបស់ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី ដែលតំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម លេខ ១៥៨៥/០៦ ពណ.ចបព ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ ក្រុមហ៊ុននេះគឺជារោងចក្រ អាល់កុល ដើម្បីផលិតផលិតផលសំខាន់ៗដូចជា អេទីលអាល់កុល អាល់កុលសុទ្ធ អាល់កុលឆៅ ផលិតទឹកកកស្ងួត ចំណីសត្វ ឧស្ម័នកាបូនិច និងផ្សេងៗទៀត ដែលជាផលិតផលបន្ថែមរបស់រោងចក្រ អេតាណុល។ ក្រុមហ៊ុននេះបានចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ Inv.១១៧១ E/២០០៧ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៧។ នៅក្នុងសវនាការ ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនមានជួលកម្មករនិយោជិតសរុបចំនួន ៩៧ នាក់។
- នៅក្នុងក្រុមហ៊ុន មានការបោះឆ្នោតបង្កើតសហជីពមូលដ្ឋាន ដែលមានឈ្មោះសហជីពអំណាចកម្មករខ្មែរ ប៉ុន្តែ សហជីពកំពុងរង់ចាំវិញ្ញាបនប័ត្រចុះបញ្ជិកាពីក្រសួងការងារ បន្ទាប់ពីការស្នើសុំចុះបញ្ជិកា ដោយមានបង្កាន់ដៃស្នើសុំចុះបញ្ជិកា ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣។ យោងតាមលិខិតពឹងពាក់ និងផ្ទេរសិទ្ធិ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ មានកម្មករនិយោជិតចំនួន ២២ នាក់ ជាដើមបណ្តឹង បានធ្វើការផ្ទេរសិទ្ធិឱ្យសហព័ន្ធសហជីពអំណាចកម្មករខ្មែរ ដើម្បីដោះស្រាយវិវាទ ក្នុងសំណុំរឿងនេះ។

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយមួយខែ ដល់កម្មករនិយោជិត**

- ការអនុវត្តក្នុងក្រុមហ៊ុន និយោជកមិនធ្លាប់ផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតទេ។

- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
    - ប្រាក់ឈ្នួលរបស់កម្មករនិយោជិតមានចំនួនតិច
    - ស្នើសុំឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដូចកម្មករនិយោជិតដែលបានធ្វើការនៅផ្នែកវាយភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងផងដែរ ។
- ភាគីនិយោជកបានអះអាងថា និយោជកមិនមានលទ្ធភាពផ្តល់ឱ្យភាគីកម្មករនិយោជិតតាមការទាមទារទេ ។ ភាគីនិយោជកបានបន្តទៀតថា និយោជកបានផ្តល់ឱ្យអត្ថប្រយោជន៍បន្ថែម ដែលប្រសើរជាងច្បាប់កំណត់ ដូចជា ប្រាក់សោហ៊ុយធ្វើដំណើរចំនួន ០.៨៥ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ នៃថ្ងៃ ដែលកម្មករនិយោជិតបានមកធ្វើការ, ប្រាក់ថ្លៃបាយចំនួន ១.៥ ដុល្លារអាមេរិក ក្នុងមួយថ្ងៃ នៃថ្ងៃ ដែលកម្មករនិយោជិតបានមកធ្វើការ និងប្រាក់លើកទឹកចិត្តចំនួនពី ១.៥ ភាគរយ(%) ទៅ ៣ ភាគរយ (%) នៃប្រាក់ឈ្នួលគោល (ប្រាក់ឈ្នួលអប្បបរមា) ដែលកម្មករនិយោជិតបានទទួលក្នុងមួយខែ ។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិត**

- នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានបញ្ជាក់ពីការទាមទារថា ស្នើសុំឱ្យនិយោជកផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិតតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ។
- ការអនុវត្តក្នុងក្រុមហ៊ុន និយោជកមិនធ្លាប់ផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិតទេ ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
    - និយោជកគប្បីផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិត ដូចកម្មករនិយោជិតដែលបានធ្វើការនៅផ្នែកវាយភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែរ ។
    - កម្មករនិយោជិតមានជីវភាពលំបាក ពីព្រោះទទួលបានប្រាក់ឈ្នួលប្រចាំខែមានចំនួនតិច ។
- ភាគីនិយោជកបានអះអាងថា និយោជកមិនមានលទ្ធភាពផ្តល់ឱ្យកម្មករនិយោជិតតាមការទាមទារទេ ។ ភាគីនិយោជកបានលើកឡើងថា នៅឆ្នាំ២០០៩ និងឆ្នាំ២០១០ គឺក្រុមហ៊ុនធ្លាប់ផ្អាកដំណើរការ ពីព្រោះនិយោជកជួបប្រទះបញ្ហាហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរ ។ លើសពីនេះទៀត ភាគីនិយោជកបានបន្តទៀតថា ក្រុមហ៊ុននេះគឺជាប្រភេទក្រុមហ៊ុនផលិត អាល់កុល ដែលមានលក្ខណៈខុសគ្នាពីក្រុមហ៊ុននៅផ្នែកវាយភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**ចំណុចវិវាទទី ១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយមួយខែ ដល់កម្មករនិយោជិត**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើភាគីនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិត ដែរឬទេ?

មូលហេតុនៃការទាមទាររបស់ភាគីកម្មករនិយោជិត គឺ កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលតិច និងចង់ទទួលបានប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដូចកម្មករនិយោជិតនៅវិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែរ ។

យោងតាមសេចក្ដីជូនដំណឹងលេខ ២៣០ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ចែងថា*"គោរពតាមអនុសាសន៍... បានធ្វើការប្រជុំពិភាក្សា អំពីការផ្ដល់អត្ថប្រយោជន៍ផ្សេងៗ សម្រាប់កម្មករនិយោជិត ធ្វើការនៅផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ។*

*...*

*២-កម្មករនិយោជិតដែលបានមកធ្វើការទៀងទាត់តាមចំនួនថ្ងៃ នៃថ្ងៃធ្វើការក្នុងខែនីមួយៗ ដោយគ្មានអវត្តមាន ត្រូវទទួលបានប្រាក់រង្វាន់យ៉ាងតិចចំនួន ១០ (ដប់) ដុល្លារសហរដ្ឋ អាមេរិក ក្នុងមួយខែ ។..."*

ក្នុងសំណុំរឿងលេខ ០៣/១៣-តៃ វ៉ាង ព្រីនធីង ហេតុផលចំណុចវិវាទទី៤ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា *" យោងតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងខាងលើនេះ ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ អនុវត្តចំពោះតែផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ តទៅ ។... ក្រុមហ៊ុនតៃ វ៉ាង ព្រីនធីង ជាប្រភេទក្រុមហ៊ុនផលិតប្រអប់ដាក់ស្បែកជើង ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា ក្រុមហ៊ុន តៃ វ៉ាង ព្រីនធីង មិនស្ថិតនៅក្រោមវិសាលភាពនៃសេចក្ដីជូនដំណឹងលេខ ២៣០ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ទេ ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលខាងលើដែរ ។

នៅក្នុងសំណុំរឿងនេះ ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី ជាក្រុមហ៊ុនផលិតអាល់កុល ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី មិនស្ថិតនៅក្រោមវិសាលភាពនៃសេចក្ដីជូនដំណឹងលេខ ២៣០ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២ ទេ ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកមិនឃើញថា មានបទប្បញ្ញត្តិច្បាប់ការងារ អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬការអនុវត្តកន្លងមកណាមួយ ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកក្នុងការផ្ដល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ ដល់កម្មករនិយោជិតទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ចំណុចវិវាទនេះ គឺជាវិវាទអំពីផលប្រយោជន៍ ។

ចំពោះវិវាទអំពីផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាដូចខាងក្រោម ៖

កថាខណ្ឌទី២ នៃមាត្រា៩៦ នៃច្បាប់ស្ដីពីការងារ ចែងថា ៖ *"អនុសញ្ញារួម គឺជាកិច្ចព្រមព្រៀង ជាលាយលក្ខណ៍អក្សរ ដែលទាក់ទងដល់បទប្បញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងមាត្រា៩៦ កថាខ័ណ្ឌទី១ អនុសញ្ញារួម ត្រូវធ្វើឡើងដោយព្រមព្រៀងគ្នារវាង ៖*

*ក. មួយចំណែកគឺនិយោជកម្នាក់ និយោជកមួយក្រុម ឬអង្គការមួយ ឬអង្គការច្រើនតំណាងឱ្យនិយោជក" ។*

*ខ. មួយចំណែកទៀត គឺអង្គការសហជីពមួយ ឬអង្គការសហជីពច្រើនតំណាងឱ្យកម្មករនិយោជិត ។... "*

លើសពីនេះ ប្រការ៩ នៃប្រកាសលេខ ៣០៥ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ចែងថា ៖ *"សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចា អំពីអនុសញ្ញារួម ដែលអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ។ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ចត្រូវតែធ្វើការចរចាជាមួយសហជីព។"*

យោងតាមមាត្រា ៩៦ នៃច្បាប់ស្តីពីការងារ និងប្រការ៩ នៃប្រកាសខាងលើ ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណា លើភាពជាតំណាងបំផុតរបស់សហជីពដែលជាភាគីវិវាទ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីព ផ្តល់សិទ្ធិតាមផ្លូវច្បាប់ដល់សហជីពក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ ក្នុងការនាំសំណុំរឿងវិវាទអំពីផលប្រយោជន៍ មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ។

ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលដោះស្រាយវិវាទផលប្រយោជន៍ នឹងត្រូវមកជំនួសអនុសញ្ញារួម និងមានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ"*។

យោងតាមខ្លឹមសារនៃប្រការ ៤៣ នៃប្រកាសខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីផលប្រយោជន៍ នឹងក្លាយជាអនុសញ្ញារួម ដែលអនុវត្តទៅលើកម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន ហើយធ្វើឱ្យកម្មករនិយោជិតទាំងអស់ បាត់បង់សិទ្ធិក្នុងការធ្វើកូដកម្មដើម្បីទាមទារលើវិវាទដែលទាក់ទងនឹងផលប្រយោជន៍នាពេលអនាគត។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចធ្វើការដោះស្រាយវិវាទអំពីផលប្រយោជន៍បាន លុះត្រាតែសហជីពដែលទាមទារនាំយកវិវាទនោះមក ជាសហជីពដែលមានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស ឬសហជីពច្រើនរួមគ្នាទៅមានចំនួនសមាជិកលើសពីពាក់កណ្តាលនៃកម្មករនិយោជិតនៅក្នុងសហគ្រាស (សូមមើលសេចក្តីបង្គាប់ *លេខ ៨១/០៤-អេវើហ្គ្រីន ចំណុចវិវាទទី៤ និងលេខ ៩៨/០៤-ប្រេក្កត យូនៀន ចំណុចវិវាទទី៣*)។

នៅក្នុងសំណុំរឿងលេខ ១៦៩/១១-ហ៊ូវធៀន ធីវ គ្រង់ចំណុចវិវាទទី៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណាវិវាទអំពីផលប្រយោជន៍ ដោយសារសហជីពដែលនាំវិវាទការងារនោះ មកជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ០២/១១-ពូយៀន ហេតុផលចំណុចវិវាទទី២ និងលេខ ៦៦/១១-អ៊ិនហាន់ស៊ីង ហេតុផលចំណុចវិវាទទី១*)។

នៅក្នុងសំណុំរឿងនេះ មានកម្មករនិយោជិតចំនួន ២២ នាក់ ជាដើមបណ្តឹង បានធ្វើការផ្ទេរសិទ្ធិឱ្យសហព័ន្ធសហជីពអំណាចកម្មករខ្មែរ ដើម្បីដោះស្រាយវិវាទ គឺពួកគាត់មិនមែនជាអង្គការវិជ្ជាជីវៈ ឬសហជីពដែលមានភាព

ជាតំណាងបំផុតប្រចាំក្រុមហ៊ុន អិម អេច បាយអូ-អេនើជី ទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ២២ នាក់ ជាដើមបណ្តឹង គឺមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ ក្នុងការនាំវិវាទដែលទាក់ទងនឹងផលប្រយោជន៍ មកក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណានោះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយមួយខែ ដល់កម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជក ផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិត យោងតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើភាគីនិយោជកមានកាតព្វកិច្ចប្រាក់អតីតភាពការងារ ដល់កម្មករនិយោជិត យោងតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ដែរ ឬទេ?

មូលហេតុនៃការទាមទាររបស់កម្មករនិយោជិត គឺ កម្មករនិយោជិតមានជីវភាពលំបាក ពីព្រោះទទួលបានប្រាក់ឈ្នួលប្រចាំខែមានចំនួនតិច និងចង់ទទួលបានប្រាក់រង្វាន់អតីតភាពការងារ ដូចកម្មករនិយោជិតនៅផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងដែរ។

សេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១១ ចែងថា " *គោរពតាមអនុសាសន៍... អំពីការផ្តល់អត្ថប្រយោជន៍ផ្សេងៗ ដូចជា ... ប្រាក់អតីតភាពការងារ ជូនកម្មករនិយោជិត ធ្វើការផ្នែកវាយនភ័ណ្ឌ កាត់ដេរ និង ផលិត ស្បែកជើង ។*

...

*៣-ប្រាក់រង្វាន់អតីតភាពការងារ*

*ក- កម្មករនិយោជិតដែលធ្វើការនៅក្នុងរោងចក្រ សហគ្រាស គ្រឹះស្ថានណាមួយ លើសពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារដូចមាននៅក្នុងតារាងខាងក្រោមនេះ ៖*

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| *អតីតភាពការងារ គិតជាឆ្នាំ* | *១* | *២* | *៣* | *៤* | *៥* | *៦* | *៧* | *៨* | *៩* | *១០* | *១១* |
| *ចំនួនទឹកប្រាក់ទទួលបានក្នុងមួយខែគិតជាដុល្លារអាមេរិក* | *០* | *២* | *៣* | *៤* | *៥* | *៦* | *៧* | *៨* | *៩* | *១០* | *១១* |

*ខ- កម្មករនិយោជិត មានអតីតភាពការងារនៅឆ្នាំណា ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារនៅក្នុងឆ្នាំនោះ (ដូចតារាងខាងលើ) លើកលែងតែកម្មករនិយោជិត ដែលមានអតីតភាពការងារនៅក្នុងឆ្នាំទី ១១ គឺ ចំនួន ១១ (ដប់មួយ) ដុល្លារអាមេរិក ក្នុងមួយខែ ។... ។*

យោងតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សេចក្តីជូនដំណឹងនេះធ្វើឡើងសម្រាប់តែកម្មករនិយោជិតផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងប៉ុណ្ណោះ

គឺមិនសំដៅទៅលើការផ្តល់ជូនកម្មករនិយោជិត ដែលបម្រើការងារនៅផ្នែកផ្សេងៗឡើយ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៨៩/១២-ស៊ី ភី ហេតុផលចំណុចវិវាទទី៦ )* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះរកឃើញថា ក្រុមហ៊ុន អិម អេច បាយអូ -អេនើជី ជាក្រុមហ៊ុនផលិតអាល់កុល គឺមិនមែនជាក្រុមហ៊ុនដែលនៅផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងទេ។ ដូចនេះ ក្រុមហ៊ុន អិម អេច បាយអូ-អេនើជី គឺមិនស្ថិតនៅក្រោមវិសាលភាពនៃសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ទេ។

ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកមិនឃើញថា មានបទប្បញ្ញត្តិច្បាប់ការងារ អនុសញ្ញារួម កិច្ចព្រមព្រៀងណាមួយរវាងភាគីទាំងពីរ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ឬការអនុវត្តកន្លងមកណាមួយ ដែលកំណត់អំពីកាតព្វកិច្ចរបស់និយោជកផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិត ដែលបម្រើការងារនៅក្រុមហ៊ុន អិម អេច បាយអូ-អេនើជី ដែលជាក្រុមហ៊ុនផលិតអាល់កុល យោងតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ ទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចំណុចវិវាទនេះ គឺជាវិវាទអំពីផលប្រយោជន៍។ (សូមមើលការបកស្រាយស្តីអំពីវិវាទអំពីផលប្រយោជន៍នៅក្នុងហេតុផលសេចក្តីសម្រេចចំណុចវិវាទទី១ ខាងលើ)។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់អតីតភាពការងារដល់កម្មករនិយោជិត យោងតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ១ ៖**

បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយមួយខែ ដល់កម្មករនិយោជិត។

**ចំណុចវិវាទទី ២ ៖**

បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកផ្តល់ប្រាក់រង្វាន់អតីតភាពការងារ ដល់កម្មករនិយោជិត យោងតាមសេចក្តីជូនដំណឹងលេខ ០៤១/១១ ក.ប/ស.ជ.ណ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

ARBITRATION COUNCIL

ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **ឈើង គិរម្យ**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន និម្មិត**

ហត្ថលេខា ៖ ------------------------------